# ពិធីអស្វមេធក្នុងសង្គមខ្មែរសម័យបុរាណ

## តើអស្វមេធជាអ្វី?

***អស្វមេធ*** ជាភាសាសំស្ក្រឹតមានន័យថា អស្វ (សេះ[១]) +មេធ= ការបូជាសេះ[២] ជាពិធីក្នុងគម្ពីរវេទ គឺជាការធ្វើចំបាំងដណ្ដើមយកនគររបស់អាណាចក្រមួយ ក្នុងរយៈពេល១ឆ្នាំ ដោយការប្រើសេះដ៏ល្អមួយ។ វាជាពិធីមួយក្នុងចំណោមពិធីសំខាន់ៗ៤ក្នុងគម្ពីរវេទបុរាណរបស់ឥណ្ឌា ដែលពិធីនេះអាចប្រារព្ធធ្វើទៅបានតែព្រះមហាក្សត្រប៉ុណ្ណោះ ដើម្បីទទួលនូវអំណាច ឥទ្ធិពល ភាពល្បីខ្ចរខ្ចារ ភាពចម្រុងចម្រើន និងភាពមានអំណាចលើប្រទេសជិតខាង។ ពិធីនេះត្រូវបានពិពណ៌នានៅក្នុងគម្ពីរ*ឫគវេទ* *យជុវេទ* និង*សតបថព្រាហ្មណ៍* ដែលត្រូវបានចងក្រងឡើងនៅចន្លោះរវាងឆ្នាំ៩០០ទៅ៧០០មុនគ្រិស្តសករាជ។[៣] ពិធីនេះគឺចង់បង្ហាញពីអធិរាជឬស្ដេចដ៏ខ្លាំងក្លាក្នុងអាណាចក្រមួយ ដោយចង់បង្ហាញនូវអំណាចនិងកំលាំងរបស់ព្រះអង្គ ព្រះអង្គជ្រើសរើសយកសេះដ៏ល្អ និងខ្លាំងមួយ និងហែហមដោយរាជបុត្រ កូនមន្ត្រីធំ និងទ័ពយ៉ាងច្រើន រួចឱ្យសេះដើរដោយសេរីទៅកាន់ប្រទេសជិតខាង។ នៅពេលសេះទៅដល់ប្រទេសណា ឬតំបន់កាន់កាប់ដោយស្ដេចត្រាញ់ណា ស្ដេច ឬស្ដេចត្រាញ់ត្រូវតែនាំយកសួយសាអាករមកថ្វាយ បើមិនដូច្នោះទេ ទ័ពដែលហែហមសេះនិងវាយកំទេច។ ក្រោយដើរអស់រយៈពេល១ឆ្នាំ ពេលត្រឡប់មកវិញ គេនឹងធ្វើពិធីអស្វមេធនេះ។ តែបើសិនជាសេះ និងអ្នកហែហមត្រូវបានវាយបង្ក្រាបដោយប្រទេសណាមួយក្នុងកំឡុងពេលត្រាចរនោះ នោះពិធីនេះនឹងមិនត្រូវបានប្រារព្ធឡើងទេ ហែយ គេនឹងចំអកឱ្យថា ស្ដេចឬអធិរាជនេះអន់ខ្សោយ។

## ពិធីអស្វមេធក្នុងទេវកថា

ពិធីនេះបង្ហាញផងដែរនៅក្នុងវិរៈកថាឥណ្ឌា ដូចជា *មហាភារត* (Mahābhārata) និង *រាមាយណៈ* (Rāmāyana)។ ជាក់ស្ដែងនៅក្នុងរឿងមហាភារត ការបូជាត្រូវបានធ្វើឡើង

---

[១] Philip N. Jenner, 2009:731

[២] Gérard Huet, 2020:103

[៣] Roman Zaroff, 2005:75-86

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ដោយ *យុធិស្ថិរ* (Yudhistira) ដោយបងប្អូនប្រុសរបស់គាត់ជាអ្នកមើលសេះ ក្នុងខណៈពេលដែលវាដើរទៅកាន់អាណាចក្រនៅក្បែរផ្សេងៗ។ ពេលនោះ អរជុនបានយកឈ្នះរាល់អ្នកបង្កជម្លោះ។ រឿងមហាភារតបង្ហាញថា ពិធីអស្វមេធដែលបានធ្វើឡើងដោយ យុធិស្ថិរ មានទំនាក់ទំនងយ៉ាងជិតស្និតទៅនិងសំបុត្រនៃញាត្តិគម្ពីវេទ។ បន្ទាប់ពីសេះត្រូវបានគេកាត់ក្បាលនិងជាបំណែក *ទ្រោបតិ* (Dropati) ត្រូវតែអង្គុយក្បែរបំណែកទាំងអស់របស់សេះនោះ។ ចំណែនៅក្នុងរឿងរាមាយាណៈ បិតារបស់ព្រះរាម *ទសរថ* (Dasarath) បានប្រារព្ធពិធីអស្វេមធ ដែលត្រូវបានពិពណ៌នានៅក្នុងកំណាព្យ *បលកនដ* (Palakanaṭa)។ រឿងរាមាយណៈបង្ហាញវែងឆ្ងាយជាងរឿងមហាភារត អំពីពិធីអស្វមេធ។ ពិធីអស្វមេធត្រូវបានប្រព្រឹត្តិទៅក្នុងរយៈពេល៣ថ្ងៃ ដោយអនុវត្តដោយបណ្ឌិត *ឫស្យាស្រិង្គ* (Ṛsyāsriṅga) និង*វសិស្ត*[៨] (Vasista)។

## ដំណើរនៃពិធីអស្វមេធ

សាច់រឿងនៃពិធីអស្វមេធ គឺជាពិធីបូជាមួយទាក់ទងទៅនឹងសត្វសេះមួយដែលត្រូវបានលែង និងអនុញ្ញាតិឱ្យដើរដោយសេរីក្នុងរយៈពេលពេញមួយឆ្នាំ ហែយវាត្រូវបានហែហមដោយ១០០ព្រះអង្គម្ចាស់ ១០០នាក់នៃកូនប្រុសរបស់មេដឹកនាំផ្សេងៗ និង១០០នាក់នៃកូនប្រុសរបស់អ្នកចូលរួមនិងអ្នកបរទេះ ដែលម្នាក់ៗប្រដាប់ដោយអាវុធទៅតាមឋានៈរៀងៗខ្លួន។[៩] ការលុកលុយរបស់សេះលើអាណាចក្រ និងតំបន់ជុំវិញ គឺជាការប្រកួតប្រជែងជាមួយនឹងអ្នកគ្រប់គ្រងលើតំបន់ទាំងនោះ។ ប្រសិនបើអ្នកហែហមត្រូវបានវាយប្រហារនិងធ្វើឱ្យបរាជ័យដោយប្រទេសឬតំបន់ណាមួយ ឬក៏សត្វសេះត្រូវបានគេចាប់នោះពិធីនិងមិនត្រូវបានប្រារព្ធឡើយ។ ផ្ទុយទៅវិញ វានិងក្លាយជាស្តេចដែលគេសើចំអកនិងមិនខ្លាំងក្លា។ ដូច្នោះ ដើម្បីជានាទូវជ័យជំនះនេះ អ្នកហែហមមិនត្រឹមតែការពារសត្វសេះជាមួយនិងអ្នកវាយប្រហារទេ ពួកគេត្រូវតទល់ប្រឆាំងនិងគ្រោញថ្នាក់ផ្សេងៗដែលទស្សទាយមិនបាន ដូចជាការរួមសង្វាស់ជាមួយសេះញី ឬការមានជំងឺរបស់សេះនេះ។ អ្នក

---

[៨] http://en.wikipedia.org/wiki/Ashvamedha

[៩] Vittorio Roveda, (2005:116-118)

*ហែហមដែលនៅមានជីវិត និងក្បួនទ័ពដែលចេញច្បាំង គឺមានសិទ្ធិចែករំលែកអំណាចព្រះរាជាដែលបានមកពីការប្រារព្ធនៃពិធីអស្វមេធ។ ការត្រលប់មកវិញរបស់សេះ គឺជាសញ្ញាមួយផងដែរនៃការឧទ្ទិសរបស់ព្រះរាជា។ សត្វសេះត្រូវបានសម្អាតដោយទឹក និងនាំទៅកាន់ទីកណ្តាលនៃធាកជាមយយនិងសត្វដែលត្រូវបូជាដទៃទៀត។ បន្ទាប់មក វាត្រូវបានសំលាប់ដោយប្រើកាំបិតមាស ក្នុងដំណើរការនៃពិធី។ ពិធីនេះបញ្ចប់ដោយព្រឹត្តិការណ៍ដ៏អស្ចារ្យនៃការស្រោចទឹកដល់អ្នកចូលរួមទាំងឡាយ និងការចែកទានដល់បុព្វជិតដែលជារឿយៗត្រូវបាននាំមកពីសត្រូវក្នុងខណៈពេលដែលសត្វសេះធ្វើដំណើរទៅកាន់តំបន់នានា។*

## ***ពិធីអស្វមេធក្នុងទិដ្ឋភាពប្រវត្តិសាស្ត្រ***

*តាមរយៈប្រវត្តិសាស្ត្រឥណ្ឌាបុរាណ ស្តេចព្រះនាម សមុទ្រគុនត*(*គ.ស៣៣៥ដល់គ.ស៣៧៥*) *ដែលត្រូវបានបង្ហាញនៅក្នុងសិលាចារឹករបស់អ្នកស្នងរាជ្យបន្តពីគាត់ បានធ្វើឡើងវិញនូវការបូជាសេះ។ លើសពីនេះ ក៏បានបង្ហាញនៅថ្ងៃចុងក្រោយនៃចម្បាំងរបស់គាត់ ដោយគាត់បានផ្តល់នូវទានដែលមានចំនួនយ៉ាងច្រើនក្នុងពេលធ្វើពិធី ហើយនឹងរំលឹកដល់ពិធីនេះ គាត់បានចេញកាក់មាស។*[៦]

*ក្រៅពីអត្ថបទឥណ្ឌា នៅក្នុងសម័យអាណាចក្រខ្មែរ* (*កម្ពុជា*) *អស្វមេធត្រូវបានបង្ហាញម្តងនៅក្នុងសិលាចារឹកសតវត្សទី១០* (K.805[៧]) *ជាសិលាចារឹករបស់ប្រាសាទប្រែរូបក្នុងរាជ្យព្រះបាទ រាជេន្ទ្រវរ្ម័នទី២* (*គ.ស៩៤២ដល់៩៦៨*)*។ ពិធីពិសេសនេះប្រហែលជាត្រូវបានប្រារព្ធធ្វើផងដែរ ក្នុងរាជ្យរបស់ព្រះបាទសូរ្យវរ្ម័នទី១* (*គ.ស១០០២ដល់គ.ស១០៥០*) *គឺសតវត្សទី១១។ ការចាប់ផ្តើមឡើងនៃរាជ្យរបស់ព្រះអង្គ គឺការជួបប្រទះសង្គ្រាមក្នុងស្រុកជាសង្គ្រាមដណ្តើមរាជ្យគ្នារវាងព្រះអង្គ និងព្រះបាទជ័យវីរវរ្ម័ន* (*គ.ស១០០១ ដល់គ.ស១០១០*) *អស់រយៈពេលយ៉ាងយូរ។ នៅចុងក្រោយព្រះអង្គបានទទួលជ័យជំនះ និងឡើងគ្រងរាជ្យលើអាណាចក្រខ្មែរទាំងមូលក្រោមការបង្រួបបង្រួមតំបន់នានា និងបង្ខំឱ្យមន្ត្រី*

---

[៦] Rama Shankar Tripati, 1992

[៧] G. Cœdès, 1937:73-142

មួយចំនួនដែលមានភក្តីភាពជាមួយព្រះបាទជ័យវីរវរ្ម័ន ចុះចូលនិងស្ម័គ្រស្មោះនិងព្រះអង្គវិញជារៀងរហូត។

ជាកស្តុតាង ផ្តែរមួយដែលប្រហែលជាមកពីទ្វារចូលណាមួយរបស់ប្រាសាទភិមៃ ហើយឥលូវកំពុងដាក់បង្ហាញនៅក្នុងសារមន្ទីរភិមៃ។ វាបង្ហាញពីឈុតមួយ អាចជាប់ទាក់ទងនិងពិធីអស្វមេធ គឺមានមនុស្ស ឬព្រាហ្មណ៍ម្នាក់កាន់ថូមានជំពុយ (*កន្ទីឬកុន្ទី*[1]) ស្រោចទឹកទៅលើបាតដៃរបស់មនុស្សម្នាក់ទៀត ក៏ដូចជាស្រោចទៅលើក្បាលសេះផងដែរ។ វាអាជាឈុតចុងក្រោយនៃពិធីអស្វមេធ គឺការកាត់ក្បាល ឬបូជាសេះ បន្ទាប់ពីការត្រលប់មកវិញនៃដំណើរដោយសេរីជុំវិញអាណាចក្រក្នុងរយៈពេលមួយឆ្នាំ។ អត្ថន័យនៃពិធីនេះទាក់ទងទៅនិងសត្វសេះ និងការបង្ហាញអំពីអំណាច ភាពរុងរឿងរបស់ព្រះរាជា ឬស្តេច ចំពោះស្តេចត្រាញ់ ឬព្រះអង្គម្ចាស់ដទៃទៀតនៅក្នុងអាណាចក្រខ្លួន ឬប្រទេសចំណុះជិតខាងដទៃ។

សរុបសេចក្តីមក យើងឃើញថា ពិធីអស្វមេធ ជាពិធីដ៏សំខាន់មួយក្នុងគម្ពីរវេទ ដែលបង្ហាញអំពីវីរភាព (វីរកថា) របស់ព្រះរាជា ឬអធិរាជដែលគ្រប់គ្រងក្នុងអាណាចក្រមួយតាមរយៈការធ្វើការធ្វើចម្បាំង ឬលុកលុយទៅលើប្រទេសឬតំបន់ជុំវិញអាណាចក្ររបស់ខ្លួន។ វាជាសកម្មភាពដែលបង្ហាញពីអំណាច និងកំលាំងរបស់អធិរាជនោះ តែផ្ទុយទៅវិញ ប្រសិនបើសកម្មភាពនេះត្រូវបានកំទេចដោយប្រទេសណាមួយនោះ គេនិងចំអកថាជាស្តេចឬអធិរាជដែលតន់ខ្សោយ។ បើលទ្ធផលទទួលបានជោគជ័យ ពិធីអស្វមេធ ឬបូជាសេះនឹងប្រារព្ធឡើង ជាការអបអរ និងប្រទានអ្វីដល់អ្នកចូលរួមច្បាំង និងពពួកព្រាហ្មណ៍ដែលនាំមកពីប្រទេសឬតំបន់នានា។

ពិធីនេះហាក់បីដូចជាពុំមានបង្ហាញជាចំហក្នុងសង្គមខ្មែរបុរាណទេ តែតាមរយៈសិលាចារឹកមួយចំនួនបង្ហាញ ឬភ្ជាប់វីរភាពរបស់ស្តេចទៅនិងអ្វីដែលជាដំណើររឿង ឬសកម្មភាពនៅក្នុងពិធីមួយនេះ។ តាមផ្ទាំងចំលាក់លើផ្តែរ ក៏អាចឱ្យយើងសន្និដ្ឋានបានខ្លះថាក្រោយពេលដែលព្រះបាទសូរ្យវរ្ម័នទី១ បានទទួលការគ្រប់គ្រងលើអាណាចក្រទាំងមូល

[1] Sok Keo Sovannara, (2009:226)

ហើយព្រះអង្គអាចរំលឹកអំពីសកម្មភាពដែលព្រះអង្គបានតស៊ូ ហើយអាចរៀបចំធ្វើពិធីនេះឡើងផងដែរ ត្បិតពុំមានសិលាចារឹកណាមួយចង្អុលបង្ហាញលំអិតពីដំណើរការនៃពិធីនេះ។

ឯកសារយោង


Cluade Jacques (1990), *Angkor*, Paris,.

Gérard Huet (2020), *Dictionnaire Sanskrit-Français*.

http://en.wikipedia.org/wiki/Ashvamedha.

G. Cœdès(1937), *Inscription du Cambodge*, Volume I, Hanoi.

G. Cœdès (1951), *Inscription du Cambodge*, Volume III, Paris.

Madeleine Giteau (1997), *History of Angkor*, Paris.

Philip N. Jenner (2009), *A Dictionary of Angkorian Khmer*, RSPAS, The Australian National University.

Roman Zaroff (2005), *Stdia Mythologica Slavica VIII*.

Rama Shankar Tripati (1992), *History of Ancient India*, Delhi.

Sok Keo Sovannara (2009), *Rethinking Khmer Ceramics and Metal Vessels through Ancient Inscriptions and Bas-Reliefs: Khmer Ceramic Typology through Ancient Words*, in Scientific Research on Historic Asian Ceramics, Washington D.C.

Vittorio Roveda (2005), *Image of the God*, London.




ចំលាក់លើថ្មក្នុងសារមន្ទីរគីមែ Photo: Vittorio Roveda (2005:117)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា